**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:.....៥៧ អនក្រ.បក

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតក្រុមការងារសិក្សាច្បាប់ និងលិខិតបទដ្ឋាននានា**

**ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**

---

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការ បង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៧/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- យោងតាមការចាំបាច់

**<u>ស ម្រេ ច</u>**

**ប្រការ១** : បង្កើតក្រុមការងារសិក្សាច្បាប់ និងលិខិតបទដ្ឋាននានាស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១.ឯកឧត្តម ឧត្តមសេនីយ៍ឯក | ខេង សារ៉ាឡែន | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | ប្រធា |
| ២.ឯកឧត្តម ឧត្តមសេនីយ៍ទោ | ម៉ឹក តារា | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន.អ.ជ.ប.គ.ញ | អនុប្រ |
| ៣.លោក ឧត្តមសេនីយ៍ត្រី | ម៉ៅ សែងលន់ | សមាជិកក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ | សមាជិ |
| ៤.លោក វរសេនីយ៍ឯក | សុខ ជូរ | នាយករងខុទ្ទិរប្រឆាំងគ្រឿងញៀន | សមាជិ |
| ៥.លោក | ស ធារិទ្ធ | ប្រធាននាយកដ្ឋាននីតិកម្ម អប់រំនិងស្តារនីតិសម្បទាអគ្គលេខាធិការដ្ឋាន.អ.ជ.ប.គ.ញ | សមាជិ |
| ៦.លោក | ឯម ឆាយ | អនុប្រធាននាយកដ្ឋាននីតិកម្ម អប់រំនិងស្តារនីតិសម្បទាអគ្គលេខាធិការដ្ឋាន.អ.ជ.ប.គ.ញ | សមាជ |

www.pheakdeylaw.com

៧_លោក គីម សោភ័ណ្ឌ ចៅក្រម និងជាអធិការ កិច្ចការតុលាការ ក្រសួងយុត្តិធម៌ សមាជិក

៨_លោក ស៊ីង បញ្ញារិទ្ធ ចៅក្រម និងជាប្រធាននាយកដ្ឋានអយ្យការ ក្រសួងយុត្តិធម៌ សមាជិក

៩_លោក វរសេនីយ៍ត្រី ស៊ុម សារ៉ាត់ ជំនួយការប្រធាននាយកដ្ឋានអន្តោប្រវេសន៍ សមាជិក

**ប្រការ២** : ក្រុមការងារមានភារកិច្ចដូចខាងក្រោម ៖

- សិក្សាស្វែងយល់អំពីច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀននិងលិខិតបទដ្ឋាននានា ពាក់ព័ន្ធទៅនឹងវិធានការបង្ការ ទប់ស្កាត់ និងប្រឆាំងបទល្មើសគ្រឿងញៀន ។
- សហការក្រសួងពាក់ព័ន្ធ ប្រមែប្រមូលព័ត៌មានពាក់ព័ន្ធបញ្ហាគ្រឿងញៀន ដើម្បីមានមូលដ្ឋានក្នុងការរៀបចំតាក់តែងលិខិតបទដ្ឋាននានា ឱ្យមានលក្ខណៈកាន់តែគ្រប់គ្រាន់ បំពេញសំណូមពរចាំបាច់ចំពោះមុខ និងយូរអង្វែង ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- សិក្សា ស្រាវជ្រាវចំណុចសំខាន់ៗ ដែលនៅខ្វះចន្លោះ ដើម្បីបំពេញបន្ថែមលើលិខិតបទដ្ឋាននានា សំដៅអនុវត្តច្បាប់កាន់តែមានប្រសិទ្ធិភាព ។
- ពិចារណា និងផ្តើមយោបល់ រៀបចំសេចក្តីស្នើបន្ថែមស្ថានទម្ងន់ទោសបទល្មើសគ្រឿងញៀន អំពីការកំណត់អតិបរិមានៃទម្ងន់តាមប្រភេទគ្រឿងញៀន ឱ្យបានសមស្របតាមមាត្រានីមួយៗ ដូចមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- ក្រុមការងារត្រូវបង្ហើយកិច្ចការនេះឱ្យបានចប់សព្វគ្រប់មុនដំណាច់ឆមាសទី១ ឆ្នាំ២០០៨ ដើម្បីសុំយោបល់ប្រធាន អ.ជ.ប.គ.ញ ដាក់ឆ្លងសម័យប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនលើកក្រោយ ។

**ប្រការ៣**: ក្រុមការងារមានសិទ្ធិចាត់ចែង ប្រើប្រាស់មន្ត្រីរាជការក្រោមឱវាទក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងអាចស្នើសុំមន្ត្រីជំនាញពីក្រសួងស្ថាប័ននានា ជាសមាជិក អ.ជ.ប.គ.ញ ដើម្បីជួយការងារតាមការចាំបាច់ ។

**ប្រការ៤**: ក្រុមការងារ ត្រូវចូលរួមប្រជុំ និងបំពេញភារកិច្ចតាមការអញ្ជើញ និងការណែនាំរបស់ប្រធាន ។

**ប្រការ៥**: ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសមាសភាពដែលមានចែងក្នុងប្រការ១ និងប្រការ៤ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០០៧

ឧបនាយករដ្ឋមន្ត្រី

ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ស ខេង

*កន្លែងទទួល*

*ស្ងួងព្រះបរមរាជវាំង*

*រលេខាធិការដ្ឋានព្រឹទ្ធសភា*

*រលេខាធិការដ្ឋានរដ្ឋសភា*

*កាល័យសម្តេចនាយករដ្ឋមន្ត្រី*

*ប្រការ ១ និង ៥*

*សារ_កាលប្បវត្តិ*

www.pheakdeylaw.com